*[អ្នកនិយាយ៖ ជី មុនីវង់]*
*[Speaker: Chi Monivong]*

[00:00]

ការចាប់ផ្ដើមអង្គួច គឺខ្ញុំចាប់ផ្ដើមដោយប្រើប្រាស់ឧបករណ៍មួយចំនួនដូចជា៖ ដែកដាប់មួយ កាំបិតបន្ទោះមួយ និងពូថៅមួយសម្រាប់ចោះអណ្ដាតវា។ ខ្ញុំចាប់ផ្ដើមធ្វើដោយការពុះរបៀបនេះ។ ពុះល្មមសម្រាប់ការធ្វើរាល់ថ្ងៃដូចដែលខ្ញុំបានចំណាំវា!
I start to make Angkuoch by having a few tools such as one chisel, one bamboo cutting knife, and an axe for making a lamella. I start by chopping [a piece of the bamboo] like this. I chop it as I did before.

ពេលដែលពុះបែបនេះរួចហើយ ខ្ញុំចាប់ផ្ដើមចិត។
ខ្ញុំទុកខាងធំនៅខាងលើសម្រាប់ធ្វើក្បាលអង្គួច។ ហើយខ្ញុំត្រូវចិតរបៀបនេះ!
មួយល្មមសម្រាប់ការធ្វើ!
When I have finished chopping, I start to carve it. I keep this bigger side for an Angkuoch’s head. And I have to carve it like this. To make it suitable for an Angkuoch!

[00:41]

សម្រាប់ខាងខ្នង ខ្ញុំត្រូវចិតសំបកវាចេញដើម្បីឱ្យមើលទៅស្អាត។
ពោះរបស់អង្គួចក៏ខ្ញុំត្រូវចិតមួយល្មមដូចដែលខ្ញុំធ្វើរាល់ថ្ងៃ! របៀបនេះ!
As for the back of a small piece of this bamboo, I need to scratch [the skin of the bamboo] to make it look beautiful. I also have to scratch the centre of this bamboo piece as I used to do earlier, every day. Like this!

សម្រាប់ការចិត ខ្ញុំត្រូវមើលបើម្ខាងទៀតតូច ខ្ញុំទុកធ្វើចុងវា។
ហើយខ្ញុំចិតបញ្ជិតទុកជាការចំណាំ។ខាងដែលធំទុកសម្រាប់ធ្វើក្បាល!
For the carving, I have to look at the size of both sides. I keep the smaller size for the tail part. I carve a line here as a marker. I keep the bigger size to make the Angkuoch’s head.

ខ្ញុំមានគម្រូមួយសម្រាប់វាស់។ ដោយសារតែខ្ញុំចំណាំមិនបាន  ខ្ញុំត្រូវធ្វើរបៀបនេះ។ ទីពីរ ខ្ញុំចិតក្បាលវា។ កាំបិតនេះមុតល្អ!
I have a sample Angkuoch to measure against. I have to copy it because I cannot remember [the measurements]. Secondly, I have to carve its head. This knife is very sharp.

រួចហើយ ខ្ញុំចិតកវា។ ខ្ញុំចិតករបៀបនេះ។ ខ្ញុំមិនអាចចិតឱ្យវាស្ដើងពេកទេ។
ខ្ញុំចិតមួយល្មមសម្រាប់ធ្វើ។ ពេលដែលយើងធ្វើរួច ខ្ញុំចិតមួយល្មម។
បើសិនជាខ្ញុំចង់ធ្វើវាឱ្យទន់ជាងនេះ... ខ្ញុំចោះវាឱ្យស្អាត។ របៀបនេះ! ប៉ុណ្ណេះល្មម!
Then, I carve its neck. I carve it like this. I shouldn’t carve it until it becomes too thin. I have to make it suitable for the Angkuoch-making. After that, I have to carve a bit more. If I want to make it to be softer than this... I make a nice hole. Like this! It is good like this.

[02:00]

បន្ទាប់មក ខ្ញុំធ្វើគន្លាក់វាសម្រាប់ចោះអណ្ដាតវាចេញ។ របៀបនេះ!
Then, I make a hole for the part of the lamella. Like this!

ខ្ញុំចាប់ផ្ដើមចោះអណ្ដាត ដោយខ្ញុំមានដែកដាប់សម្រាប់ធ្វើ។កន្លែងនេះខ្ញុំអាចចោះបាន!
កន្លែងនេះសម្រាប់ធ្វើកវា! កន្លែងនេះខ្ញុំចោះវា! ខ្ញុំចោះរបៀបនេះ។

I am making a hole with a chisel. I can make a hole in this part. This part is for its neck. I am making a hole here. I make it like this.

ខ្ញុំចោះវាឱ្យធ្លុះ ហើយវាមានភាពងាយស្រួលពេលដែលខ្ញុំចោះវាចេញមក។ របៀបនេះ!
ពេលដែលខ្ញុំចោះរួចហើយ ហើយខ្ញុំសង្កេតឃើញថាមានប្រហោង ខ្ញុំអាចយកកាំបិតមកចុច។
I am making a hole and it is easy for me to take it out. Like this! After making a hole, I have to see if it is hollow, I then can take a knife to press it with.

ខ្ញុំចុចរបៀបនេះ! *(បីដង)*
I press it like this. *[Repeats this sentence twice more.]*

ពេលដែលវាមានប្រហោងស្រេច ខ្ញុំអាចចុចវាចេញ។ ខ្ញុំយកដែកដាប់សង្កត់
ហើយវានឹងចេញរបៀបនេះ។ កន្លែងនេះមានអណ្តាត
ហើយពេលនេះខ្ញុំអាចចាប់ផ្តើមធ្វើវាបាន។ ដូច្នេះ ខ្ញុំចាប់ផ្តើមធ្វើរបៀបនេះ។
ខ្ញុំយកប្រដាប់សង្កត់ដើម្បីកុំឱ្យវារត់ទៅវិញ។ អញ្ចឹងខ្ញុំចិតវាតិចៗ ដើម្បីការពារកុំឱ្យវាខូច ឬបាក់។
When it is already hollow, I can press on it and take out the small piece of stick from lamella-making process.  I am taking a chisel to press on it and I take it out like this. Now it has a lamella and I can start to carve. I am carving it like this. I press a chisel against it so then it will not move. So then I can carve slightly to protect it from getting broken.

[03:50]

កន្លែងពិបាកធ្វើជាងគេ គឺកន្លែងនេះ។ បើខ្ញុំចិតប្រហែស វាអាចធ្លុះ ឬមិនស្មើគ្នា។
ហើយពេលដែលផ្លាត់ទៅ វាអាចនឹងខុស។ របៀបធ្វើ! គឺខ្ញុំត្រូវត្រលប់ឫស្សីមកវិញ
ដោយរក្សាដៃដដែល។ កន្លែងនេះពិបាកធ្វើជាងគេ! បន្ទាប់មក ខ្ញុំចិតអណ្តាតរបស់វា។
ខ្ញុំត្រូវមើលមួយល្មមសម្រាប់ការធ្វើ។ ដោយសារខ្ញុំដាប់មិនទាន់ដាច់
ខ្ញុំត្រូវចុចវាកន្លែងនេះបន្ថែម។ កាត់វាមួយល្មមដើម្បីឱ្យវាអាចចុចទៅវិញបាន!
អញ្ចឹងខ្ញុំសាកដែកដាប់នេះបានស្រួល!
This is the toughest part of the Angkuoch making process. If I do not pay full attention to it, it can be uneven or break easily. And if I played it, it would not sound right. I have to turn this piece of bamboo and keep my hands still. It is the toughest process. Then, I can carve its lamella. I need to see whether it is suitable not or not. Because if the piece of bamboo still sticks to the lamella part, I have to press more. Make a good cut and press! To make this process easier, I want to try to press with this chisel instead.

[04:55]

អញ្ចឹងខ្ញុំចិតអណ្តាតទាំងសងខាងឱ្យស្មើគ្នា ហើយតូចល្មម។ ចិតកន្លែងនេះមួយល្មម!
ពិបាកធ្វើកន្លែងនេះ!
I am carving both sides of the lamella to the same length.  It is hard to make this part.

[05:06]

*[មុនីវង់ ចិតសម្រួលអណ្តាតនៃអង្គួចឫស្សី]*
*[CM carves the lamella]*

[05:41]

អំបាញ់មិញ ខ្ញុំបានធ្វើរន្ធវា។ ឥឡូវនេះ ខ្ញុំត្រូវចោះចំហៀងឱ្យហើយ។ ខ្ញុំចោះ
និងត្រូវធ្វើឱ្យវាស្មើគ្នាទាំងសងខាង! ប៉ុណ្ណឹង!ឥឡូវ វាចាប់ផ្តើមបង្ហាញរូបរាងហើយ។

ខ្ញុំចាប់ផ្តើមចិតក្បាលវា។ ខ្ញុំមិនអាចផ្លុំបានទេ ប្រសិនយើងទុកក្បាលវាជ្រុងបែបនេះ។ ឥឡូវ ខ្ញុំចិតវាឱ្យស្អាត និងស្មើគ្នា។ សម្រាប់វិធីចិតក្បាល ខ្ញុំត្រូវចិតរបៀបនេះ។ អញ្ចឹង ខ្ញុំធ្វើវាឱ្យស្អាត។ ខ្ញុំមិនអាចទុកវាបែបនេះបានទេ ដោយសារវាអាចប៉ះដៃពេលផ្លុំ។ ខ្ញុំធ្វើរបៀបនេះ ហើយប៉ុណ្ណេះបាន។ ខ្ញុំចាប់ផ្តើមសម្រួលអណ្តាត ដោយសារខ្ញុំមិនអាចទុកវាឱ្យក្រាស់បានទេ  ព្រោះពេលដែលផ្លុំទៅ វានឹងមិនរលាស់។ កន្លែងនេះ ខ្ញុំចិតវាឱ្យល្មមស្អាត។
Just now, I made holes. Now I have two holes for each side. I make holes and both sides must be the same size. That’s it. Now it has the shape [of an Angkuoch]. I am starting to carve its head. I cannot play it if its head is in this condition. Now I am carving it to make it smooth and balanced. For the carving technique, I have to carve it like this. Then, I make it more beautiful. I cannot keep it like this because it will irritate the hand while playing. It is okay now. I have to improve the lamella because it cannot be thick like this. When it is thick, it will not vibrate enough. I am improving this part.

[06:47]

បើខ្ញុំមើលទៅឃើញកន្លែងណាមិនសូវស្មើរ ខ្ញុំត្រូវចិតបន្ថែម។ កន្លែងនេះ ខ្ញុំអាចចិតបាន។ ត្រង់ក្បាលហ្នឹង ខ្ញុំត្រូវចិតវាឱ្យស្អាតដើម្បីកុំឱ្យវាកូតពេលដែលខ្ញុំផ្លុំទៅ! ត្រង់ហ្នឹង! រួចខ្ញុំចោះកន្លែងនេះសម្រាបដាក់(ក្រប)អណ្តាត។ កន្លែងនេះមានការគូសចំណាំជាស្រេច! កន្លែងដែលគូសដាក់អណ្តាត  (ក្រប) គឺកន្លែងនេះ! គឺខ្ញុំត្រូវដាក់មួយល្មម និងមើលត្រង់នេះថាតើវាក្រាស់ពេក។ ខ្ញុំអាចចិតវាបានប៉ុណ្ណេះ។ ខ្ញុំអាចចាប់កន្លែងនេះទាញបាន។
If I see any imbalance in any part, I have to carve more. This spot, I can carve. I need to carve at its head [of the lamella] so it will not touch my hands when I take it to play. This one! Then I make a space here for putting on the covers. It has a mark here. A mark to put on the covers is here. I have to put them on and see whether it is suitable or it is too thick. I can carve. I can pull it out like this.

[07: 38]

បន្ទាប់ពីការធ្វើរួច ខ្ញុំត្រូវចិតជ្រុងរបស់វា ដើម្បីកុំឱ្យវាប៉ះមាត់ពេលដែលផ្លុំ។ ខ្ញុំបិតវាឱ្យស្មើ ហើយនៅពេលដែលលេង វានឹងមិនប៉ះមាត់។ វាចាប់ផ្តើមស្អាត។ បើខ្ញុំធ្វើបែបនេះ វានឹងមិនលឺពិរោះទេ។ ខ្ញុំត្រូវចិតថែមពេលដែលកវានៅរឹងបែបនេះ។ បន្ទាប់មក ខ្ញុំត្រូវការរោលភ្លើង។
After that process, I have to carve on the corners [of the small piece of the bamboo] to prevent it from cutting the mouth while playing. I have to carve until it becomes smooth and when I play, it will not cut the mouth. It is getting better now. If I keep it like this, it is still not good enough. I have to carve more when its neck is tough. Then I have to smoke it.

[08:04]

ដល់ដំណាក់កាលរោលភ្លើង ខ្ញុំត្រូវចោះកន្លែងនេះឱ្យហើយសម្រាប់ដាក់អណ្តាត(ក្រប)។ ខ្ញុំត្រូវរោលភ្លើងវា។ បានប៉ុណ្ណេះ ខ្ញុំអាចទុកវាសិន។ ខ្ញុំចាប់ផ្តើមពុះ(ក្រប)អណ្តាត។ ខ្ញុំយកកំណាត់ឫស្សីដដែលយកមកពុះមួយល្មម។ មួយល្មមសម្រាប់ខ្ញុំចិតធ្វើអណ្តាត! វិធីចិតអណ្តាត ខ្ញុំត្រូវចិតរបៀបនេះ។ ខ្ញុំចិតរបៀបនេះ។
For the process of smoking, I need to make a space here for putting on the covers [of the Angkuoch]. I need to smoke it. I can put it aside. And I can start to chop pieces of bamboo for making the covers. Just enough pieces for covers! With regard to the carving technique, I can carve it like this. I am carving it like this.

[09:06]

បន្ទាប់ពីចិតអណ្តាត(គ្របុ) រួច...រយៈពេលនៃការធ្វើ... ខ្ញុំត្រូវហាលក្តៅវា។
ខ្ញុំយកវាហាលឱ្យស្ងួត។ ឬធ្វើវិធីលឿន ខ្ញុំត្រូលរោលភ្លើង។ អញ្ចឹង ខ្ញុំរោលភ្លើង។
តែឪពុកខ្ញុំដែលធ្វើពីមុន គាត់ដាក់ហាលថ្ងៃឱ្យស្ងួត ហើយសឹមយកវាមកធ្វើ។ ចំពោះខ្ញុំឥឡូវ
ខ្ញុំចិតឫស្សីសើម រួចខ្ញុំយកវាទៅរោលភ្លើងព្រោះវាលឿនសម្រាប់ការធ្វើ។
ដំណាក់កាលនេះចប់តែប៉ុណ្ណេះ ហើយខ្ញុំអាចយកវាទៅរោលភ្លើងបាន!
ខ្ញុំចាប់ផ្តើមដុតភ្លើងរោលបាន។
After carving the covers… the process of making… I need to dry it. I take it to dry under the sun. Or, for a faster technique, I need to smoke it. So I'll prepare to smoke it now. However, what my father usually did is that he dried it under the sun first. For me, I carve damp bamboo and I smoke it. This is because it is faster. This process is done here and I can start to smoke it now. I can start burning for the smoke.

[09:44 - END]